# គម្រោងវាយតម្លៃលើផលប៉ះពាល់
# នៃលិខិតបទដ្ឋានគតិយុត្ត ( RIA ) នៅកម្ពុជា
## ហិរញ្ញប្បទានឥតសំណងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី
## លេខ 0224-CAM ( SF )

ដោយ


**យឹម ណុលសន**

**អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌**

**និង ជានាយកគម្រោង RIA**


ឧសភា ២០១៤

# មាតិកា

- ហេតុអ្វីបានត្រូវការ RIA ក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្ត?
- សាវតានៃគម្រោង RIA នៅកម្ពុជា
- គោលដៅនៃគម្រោង RIA នៅកម្ពុជា
- រចនាសម្ព័ន្ធនៃគម្រោង RIA នៅកម្ពុជា
- គោលការណ៍សំខាន់ ក្នុងការអនុវត្ត RIA នៅកម្ពុជា
- ២ តំណាក់កាល នៃការអនុវត្ត RIA នៅកម្ពុជា
- ចំណុចទាំង ៧ នៃ RIA នៅកម្ពុជា
- នីតិវិធីអនុម័តលិខិតបទដ្ឋានគតិយុត្តនៅកម្ពុជា
- ការរៀបចំ របាយការណ៍ PA ឬរបាយការណ៍ RIS
- លទ្ធផលសម្រេចបាន
- ការប្រឈម

# ហេតុអ្វីបានត្រូវការ RIA ក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្ត?

- លិខិតបទដ្ឋានគតិយុត្តត្រូវតាក់តែងឡើងដោយមានការប្រុងប្រយ័ត្ន ដើម្បីចៀសវាងកុំឲ្យមានផលប៉ះពាល់ដែលមិនបានស្មានទុក ឬផលអវិជ្ជមានផ្សេងៗ ដូចជាការរឹតបន្តឹងការប្រកួតប្រជែង ឬការដាក់បន្ទុកចំណាយដ៏ធ្ងន់ធ្ងរដែលមិនចាំបាច់ទៅលើអ្នកទាំងឡាយណាដែលរងផលប៉ះពាល់ដោយសារបទប្បញ្ញត្តិទាំងនោះ។
- រដ្ឋាភិបាលត្រូវធ្វើការវាយតម្លៃដោយប្រយ័ត្នប្រយែងពីបន្ទុក និងផលប្រយោជន៍នៃការដាក់បញ្ចូលបញ្ញត្តិកម្មថ្មី។
- RIAត្រូវបានប្រទេសជឿនលឿនជាច្រើននៃ EU និង OECD អនុវត្តសម្រាប់ការរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តឲ្យប្រសើរឡើង មានប្រសិទ្ធិភាពនិងប្រសិទ្ធិផលខ្ពស់ សូម្បីប្រទេសវៀតណាមក៏ចាប់អនុវត្តតាំងពីឆ្នាំ២០០៩មកដែរ តែតាមរូបភាពនិងទម្រង់ខុសៗគ្នា ដូចប្រទេសអូស្ត្រាលី ប្រទេសអង់គ្លេស វៀតណាម។
- ប្រទេសកម្ពុជាពុំមានបញ្ញត្តិកំណត់ពេលបញ្ចប់សុពលភាពនៃបទប្បញ្ញត្តិ (sunset clause) ហើយក៏ពុំមានយន្តការវាយតម្លៃវិសាលភាពជាន់គ្នានៃបទប្បញ្ញត្តិទាំងនោះដែរ។
- នីតិវិធីអនុវត្ត RIA នឹងធ្វើឲ្យអភិបាលកិច្ចប្រសើរឡើង ដែលជាចំណុចស្នូលនៃរបៀបវារៈរបស់រាជរដ្ឋាភិបាល ដែលបានដាក់ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ ដើម្បីសម្រេចបាននូវកំណើនសេដ្ឋកិច្ច ការងារនិងប្រសិទ្ធភាព។

# សាវតានៃគម្រោង RIA នៅកម្ពុជា

- ឆ្នាំ២០០៨ – RIA ត្រូវបានសាកល្បងអនុវត្តនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដោយមានការឧបត្ថមពីADB ក្រោមកម្មវិធីធ្វើឲ្យលិខិតបទដ្ឋានគតិយុត្តប្រសើរឡើង (Regulatory Enhancement Program)។
- ក្នុងខែឧសភា ថ្ងៃទី១៨ និងខែមិថុនា ថ្ងៃទី១ ឆ្នាំ២០១០ – ត្រូវបានចុះហត្ថលេខាលើ អនុស្សរណៈយោគយល់គ្នា ចំនួន២ រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) ទីស្ដីការគណៈមន្ត្រីជាមួយ ADB ដើម្បីប្រតិបត្តិអនុវត្តគម្រោង RIA នៅក្រោម ECOSOCC នៅទីស្ដីការគណៈមន្ត្រី។
- ខែតុលា ឆ្នាំ២០១១ – ចាប់ដំណើរការនៃក្រុមហ៊ុនទីប្រឹក្សា Pohl Consultant and Associates (មកពីប្រទេសអាឡឺម៉ង់) ផ្ដល់ការបណ្ដុះបណ្ដាលពីវិធីសាស្ត្រ RIA រៀបចំកម្មវិធី RIA និងឧបត្ថមសម្ភារៈបន្ថែមដល់ទីភ្នាក់ងារអនុវត្តគម្រោង (EA) និងទីភ្នាក់ងារប្រតិបត្តិគម្រោង (IA)។

# គោលដៅនៃគម្រោង RIA នៅកម្ពុជា

- កែលម្អភាពរឹងមាំនៃការរៀបចំតាក់តែងលិខិតបទដ្ឋានគតិយុត្ត។
- ពង្រឹងការប្រកួតប្រជែង និងប្រសិទ្ធភាពនៃលិខិតបទដ្ឋានគតិយុត្ត ។
- ផ្សព្វផ្សាយគោលការណ៍ប្រតិបត្តិល្អក្នុងការរៀបចំតាក់តែងលិខិតបទដ្ឋានគតិយុត្ត (principle of good practice in regulation making) ដល់បណ្តាក្រសួងស្ថាប័នរដ្ឋ។
- ផ្តល់ព័ត៌មានឲ្យបានច្បាស់លាស់ជូនថ្នាក់ដឹកនាំ អំពីបន្ទុកចំណាយអនុលោមតាមសំណើបញ្ញត្តិកម្ម និងផលចំណេញរបស់សំណើបញ្ញត្តិកម្ម និងជម្រើសដែលសម្រេចបានគោលដៅដូចគ្នា។
- បង្កើត website និង intranet របស់ ECOSOCC ដើម្បីងាយទទួលការពិគ្រោះយោបល់ (www.ecosocc.gov.kh)

# រចនាសម្ព័ន្ធនៃគម្រោង RIA នៅកម្ពុជា

- **ភ្នាក់ងារអនុវត្តគម្រោង (EA)** – ECOSOCC នៅទីស្តីការគណៈមន្ត្រី ដែលមាន ORIA ទទួលភារកិច្ចបណ្តុះបណ្តាល ណែនាំ គាំទ្រ ដល់ទីភ្នាក់ងារប្រតិបត្តិគម្រោង (IA) ក្នុងការអនុវត្តវិធីសាស្រ្ត RIA រៀបចំឯកសារនិងបោះពុម្ពផ្សាយ និងធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល និងបានចាត់តាំងជា៩ផ្នែក ៖
  - ផ្នែក RIA មានមន្ត្រី ៩រូប
  - ផ្នែក CBA មានមន្ត្រី ២រូប
  - ផ្នែក i-Center មានមន្ត្រី ៣រូប
  - ផ្នែក PIU (រដ្ឋបាល) មានមន្ត្រី ៣រូប
- **ទីភ្នាក់ងារប្រតិបត្តិគម្រោង (IA) ចំនួន ៧**–មាន ក្រសួងពាណិជ្ជកម្ម (MOC) ក្រសួងបរិស្ថាន (MOE) ក្រសួងទេសចរណ៍ (MOT) ក្រសួងរ៉ែ និងថាមពល (MME) ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់និងនេសាទ (MAFF) ក្រសួងអប់រំ យុវជន និងកីឡា (MEYS) ក្រសួងការងារ និងបណ្តុះបណាលវិជ្ជាជីវៈ (MLVT) ដែលមានភារកិច្ច រៀបចំធ្វើរបាយការណ៍បឋម (PA) ឬរបាយការណ៍ពេញលេញ (RIS) លើផលប៉ះពាល់នៃសំណើបញ្ញត្តិកម្ម។ ក្រុម RIA របស់ទីភ្នាក់ងារប្រតិបត្តិគម្រោងនៃក្រសួងនិមួយៗ មានមន្ត្រី ៨រូប។

# គោលការណ៍សំខាន់ក្នុងការអនុវត្ត RIA នៅកម្ពុជា

- **ផ្តល់ព័ត៌មានឲ្យបានសុក្រឹតដល់ថ្នាក់ដឹកនាំ** : RIA នឹងផ្តល់ព័ត៌មានឲ្យបានច្បាស់លាស់ពីបន្ទុកចំណាយ និងផលចំណេញនៃបញ្ញត្តិកម្ម និងជម្រើសដែលសម្រេចបានគោលដៅដូចគ្នា ជូនថ្នាក់ដឹកនាំ ដើម្បីសម្រេចដោយមានព័ត៌មានច្បាស់លាស់គ្រប់គ្រាន់។

- **ភាពងាយស្រួល** : ដោយសាធនធានមនុស្សយើងមានកំរិត យើងប្រើរូបមន្តងាយស្រួលសម្រាប់ការវិភាគ។ ផលចំណេញបានច្រើនពីនីតិវិធី RIA គឺបានមកដោយសា ការពិគ្រោះយោបល់ល្អ ភាពសមហេតុសមផល ភាពងាយស្រួលក្នុងការគណនា ចៀសជាងការប្រើរូបមន្តសេដ្ឋកិច្ចស្មុកស្មាញ។
- **តម្លាភាព** : តម្លាភាពនឹងជំរុញឲ្យធ្វើការពិគ្រោះបានល្អ និងនាំឲ្យអភិបាលកិច្ចកាន់តែប្រសើរឡើង។ ធ្វើឲ្យតម្លាភាពបានប្រសើរឡើង នឹងជួយឲ្យគម្រោងនេះសម្រេចទិសដៅបាន។

# ២ តំណាក់កាល នៃការអនុវត្ត RIA នៅកម្ពុជា

- **របាយការណ៍វាយតម្លៃបឋម – Preliminary Assessment (PA):** គ្រប់សំណើបញ្ញត្តិកម្មទាំងអស់ត្រូវធ្វើរបាយការណ៍វាយតម្លៃលើផលប៉ះពាល់បឋម (PA)។ គោលបំ ណងនៃ ការ ធ្វើរបាយការណ៍វាយតម្លៃបឋម គឺ ដើម្បីពិនិត្យលើលក្ខណៈ និងកំរិតផលប៉ះពាល់នៃសំណើបញ្ញត្តិកម្ម ទៅលើធុរកិច្ច សង្គម បរិស្ថាន ឬការប្រ គូ តប្រ ជែង ជាដំបូង។
- **របាយការណ៍វាយតម្លៃផលប៉ះពាល់ពេញលេញ – Regulatory Assessment Statement (RIS):** របាយការណ៍វាយតម្លៃលើផលប៉ះពាល់ពេញលេញ (RIS) តម្រូវឲ្យធ្វើ នៅពេលណាដែល របាយការណ៍វាយតម្លៃលើផលប៉ះពាល់បឋម (PA) បង្ហាញថាមានផលប៉ះពាល់គួរឲ្យកត់សម្គាល់។
- ទាំងរបាយការណ៍វាយតម្លៃលើផលប៉ះពាល់បឋម (PA) ទាំងរបាយការណ៍វាយតម្លៃលើផលប៉ះពាល់ពេញលេញ (RIS) ត្រូវធ្វើការវិភាគទៅតាមចំណុចទាំង ៧ នៃ RIA។ ORIA បានរៀបចំទម្រង់ណែនាំគំរូធ្វើរបាយការណ៍វាយតម្លៃលើផលប៉ះពាល់បឋម (template) ឲ្យ IA អនុវត្តតាម។

# ចំណុចទាំង ៧ នៃ RIA នៅកម្ពុជា

**បញ្ហា**

- កំណត់បញ្ហាដែលតម្រូវឲ្យមានកិច្ចអន្តរាគមន៍
- ពន្យល់ពីលក្ខណៈ ប្រភព និងទំហំនៃបញ្ហា និងរៀបរាប់ពីនរណាខ្លះដែលនឹងទទួលរងផលប៉ះពាល់
- ផ្ដល់ភស្តុតាងជាក់លាក់និងពន្យល់ថា ហេតុអ្វីបានជាលិខិតបទដ្ឋានដែលមានស្រាប់មិនអាចដោះស្រាយបាន

**គោលបំណង និងគោលដៅ**

- កំណត់គោលបំណងនិងគោលដៅនៃកិច្ចអន្តរាគមន៍ក្នុងការដោះស្រាយបញ្ហាដែលបានកំណត់ បញ្ជាក់ពី គោលបំណងនិងគោលដៅដែលជាលទ្ធផលចុងក្រោយ ប្រសើរជាងការបញ្ជាក់ពីមធ្យោបាយដើម្បីសម្រេចបានលទ្ធផល

**ជម្រើស**

- កំណត់ជម្រើសផ្សេងៗ ហើយបោះបង់ចោលជម្រើសដែលមិនអាចអនុវត្តបានឬមិនសមរម្យ និងបន្ទាប់មក រៀបរាប់ឲ្យបានលម្អិតពីជម្រើសដែលអាចអនុវត្តបាន

# ចំណុចទាំង ៧ នៃ RIA នៅកម្ពុជា (ត)

**ការវិភាគផលប៉ះពាល់**

- កំណត់ផលប៉ះពាល់របស់សំណើរបញ្ញត្តិកម្ម និងបុគ្គលឬក្រុមដែលទទួលរងផលប៉ះពាល់នោះ
- កំណត់ជាបរិមាណដែលអាចធ្វើទៅកើត នូវទំហំនិងចំនួននៃផលប៉ះពាល់ទាំងនោះ ហើយកំណត់ជាតម្លៃដើម្បីធ្វើការប្រៀបធៀបគ្នាក្នុងចំណោមជម្រើសទាំងនោះ

**ការពិគ្រោះយោបល់**

- ធ្វើការពិគ្រោះយោបល់ជាមួយភាគីរងផលប៉ះពាល់ក្នុងអំឡុងពេលនៃការរៀបចំធ្វើការវាយតម្លៃផលប៉ះពាល់នៃបញ្ញត្តិកម្ម
- ប្រើប្រាស់ព័ត៌មានដែលទទួលបានពីភាគីពាក់ព័ន្ធ ដើម្បីលើកកម្ពស់គុណភាពនៃការវិភាគ

**ការសន្និដ្ឋាន**

- កំណត់ជម្រើសដែលឃើញថាសមស្របជាងគេ និងផ្ដល់ហេតុផលលើការជ្រើសរើស ពោលគឺជម្រើសនោះនឹងធ្វើឲ្យសម្រេចគោលបំណងនិងគោលដៅនៃកិច្ចអន្តរាគមន៍ និងផ្ដល់ផលវិជ្ជមានច្រើនបំផុតដល់សេដ្ឋកិច្ចនិងសង្គម

**ការអនុវត្ត និងតាមដាន**

- ពន្យល់ពីវិធីដែលជម្រើសថាសមស្របនោះនឹងត្រូវអនុវត្តនិងវាយតម្លៃ

# បច្ចុប្បន្ន នីតិវិធីអនុម័តលិខិតបទដ្ឋានគតិយុត្តនៅកម្ពុជា

**សេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត** → **អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល** → **កិច្ចប្រជុំជំនាញបច្ចេកទេស** → **កិច្ចប្រជុំអន្តរក្រសួង** → **កិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ** → **សម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី**

**1. សេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត**

ក្រសួងសាមី

**2. អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល**

ទីស្តីការគណៈរដ្ឋមន្ត្រី

**3. កិច្ចប្រជុំជំនាញបច្ចេកទេស**

- ECOSOCC
- ក.ប.អ.ច.
- ក្រសួងសាមី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- រដ្ឋលេខាធិការ គ.រ.ម
- តំណាងខុទ្ទកាល័យ ឧប សុខអាន
- គណៈកម្មការភាសាវិទ្យាខ្មែរ

**4. កិច្ចប្រជុំអន្តរក្រសួង**

- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- រដ្ឋលេខាធិការ គ.រ.ម
- ក្រសួងសាមី
- តំណាងក្រសួងស្ថាប័នរាជរដ្ឋាភិបាល
- ECOSOCC
- ក.ប.អ.ច.
- គណៈកម្មការភាសាវិទ្យាខ្មែរ

**5. កិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ**

- ឧបនាយករដ្ឋមន្ត្រី សុខ អាន
- ECOSOCC
- ក.ប.អ.ច.
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ក្រសួងសាមី
- ក្រសួងពាក់ព័ន្ធ
- គណៈកម្មការភាសាវិទ្យាខ្មែរ

**6. សម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី**

- នាយករដ្ឋមន្ត្រី
- រដ្ឋមន្ត្រីគ្រប់ក្រសួងស្ថាប័ន

**ប្រកាស ឆ្លងរដ្ឋមន្ត្រីនៃក្រសួង**

# នៅថ្ងៃមុខ នីតិវិធីអនុម័តលិខិតបទដ្ឋានគតិយុត្តនៅកម្ពុជា

សេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត → អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល → កិច្ចប្រជុំជំនាញបច្ចេកទេស → កិច្ចប្រជុំអន្តរក្រសួង → កិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ → សម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី

**សេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត**

ក្រសួងសាមី

**អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល**

ទីស្តីការគណៈរដ្ឋមន្ត្រី

**កិច្ចប្រជុំជំនាញបច្ចេកទេស**

- ECOSOCC
- ក.ប.អ.ច.
- ក្រសួងសាមី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- រដ្ឋលេខាធិការ គ.រ.ម
- តំណាងខុទ្ទកាល័យ ឧបសុខអាន
- គណៈកម្មការភាសាវិទ្យាខ្មែរ

**កិច្ចប្រជុំអន្តរក្រសួង**

- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- រដ្ឋលេខាធិការ គ.រ.ម
- ក្រសួងសាមី
- តំណាងក្រសួងស្ថាប័នរាជរដ្ឋាភិបាល
- ECOSOCC
- ក.ប.អ.ច.
- គណៈកម្មការភាសាវិទ្យាខ្មែរ

**កិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ**

- ឧបនាយករដ្ឋមន្ត្រី សុខ អាន
- ECOSOCC
- ក.ប.អ.ច.
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ក្រសួងសាមី
- ក្រសួងពាក់ព័ន្ធ
- គណៈកម្មការភាសាវិទ្យាខ្មែរ

**សម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី**

- នាយករដ្ឋមន្ត្រី
- រដ្ឋមន្ត្រីគ្រប់ក្រសួងស្ថាប័ន

ពិគ្រោះយោបល់ជាមួយ ORIA

PA & RIS រៀបចំដោយ IA និងពិនិត្យដោយ ORIA

**ក្រុមការងារអនុវត្តគម្រោង RIA នៅECOSOCC (ORIA)** → **ប្រកាស ឆ្លង ឯ.ខ. រដ្ឋមន្ត្រីនៃក្រសួង**

# ការរៀបចំ របាយការណ៍វាយតម្លៃបឋម(PA) ឬរបាយការណ៍វាយតម្លៃពេញលេញ(RIS)



# លទ្ធផលសម្រេចបាន

- ADB បានវាយតម្លៃខ្ពស់ពីគម្រោងRIA ដែលអនុវត្តបានជោគជ័យ ហើយត្រូវបានបន្ត ៦ខែទៀត និងបញ្ចូលក្រសួងទីភ្នាក់ងារប្រតិបត្តិ (IA) ថ្មីចំនួន៣ទៀត គឺក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ (MAFF) ក្រសួងអប់រំ យុវជននិងកីឡា (MEYS) ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ (MLVT)។
- បានបោះពុម្ពផ្សាយ ឯកសារណែនាំពីវិធីសាស្រ្ត RIA (RIA guideline) និង ទម្រង់ RIA (RIA guideline) និង ទម្រង់ណែនាំគំរូធ្វើរបាយការណ៍វាយតម្លៃលើផលប៉ះប៉ះពាល់បឋម (PA template)។
- ORIA បានរៀបចំវគ្គបណ្តុះបណ្តាល ដោយខ្លួនឯងចាប់ពីខែមីនា ឆ្នាំ២០១៣។
- ក្រសួងទីភ្នាក់ងារប្រតិបត្តិ (IA) បានធ្វើរបាយការណ៍វាយតម្លៃលើផលប៉ះពាល់បឋម (PA) បញ្ញត្តិកម្មបាន២០ ហើយ PA ចំនួន ៩ និង RISចំនួន២ ទៀតកំពុងធ្វើបន្ត។
- បានធ្វើការផ្សព្វផ្សាយគម្រោង RIA នៅតាមក្រសួង សាកលវិទ្យាល័យ និងជាមួយឯកជន បាន១៧ដងមកហើយ ដែលមានអ្នកចូលរួមប្រមាណជា៣០០០នាក់ ហើយឃើញថា វិធីសាស្រ្ត RIA នេះទទួលការគាំទ្រយ៉ាងខ្លាំងពីគ្រប់សំណាក់ អ្នកចូលរួមទាំងអស់។
- ការកសាងសមត្ថភាពរបស់មន្ត្រី RIA ដើម្បីវិភាគជាប្រព័ន្ធលើទិដ្ឋភាពសេដ្ឋកិច្ចនៃបេតិកភណ្ឌទ្ធានិគតិយុត្ត នឹងបង្កើនជំនាញធ្វើគោលនយោបាយទៀតផង។

# ការប្រឈម

- RIA ងាយយល់ជាទ្រឹស្តី តែការអនុវត្តមានការលំបាកច្រើន ។
- ការដាក់ឲ្យក្រសួងទាំងអស់អនុវត្ត RIA គឺយកនីតិវិធីនិងទម្លាប់ថ្មីក្នុងការរៀបចំសំណើលិខិតបទដ្ឋានគតិយុត្ត។
- ការបណ្តុះបណ្តាលធនធានមនុស្ស ពេលវេលា សមត្ថភាព និងការប្តេជ្ញាចិត្តនៃមន្ត្រីអនុវត្ត RIA។
- ធ្វើឲ្យប្រសើរឡើងនូវគុណភាពនៃ PA និងបរិមាណ PA
- ការពិគ្រោះយោបល់ និងការចូលរួមពីផ្នែកឯកជនឲ្យមានប្រសិទ្ធិភាព។
- លើកទឹកចិត្តដល់ក្រសួងដែលអនុវត្តRIAបានល្អ
- រកធនធានគាំទ្រ i-Center ដែលជាផ្នែកសំខាន់នៃកម្មវិធីRIA

# សូមអរគុណ